មជ្ឈមណ្ឌលឯកសារកម្ពុជា

# បទសម្ភាសន៍ជាមួយមេធាវីការពារក្តី ហ្វ្រង់ស្វ័រ រូហ្ស

**ម៉ៃខឹល សាលីបា**

**ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៩**

*ប្រែសម្រួលដោយ ផា ផល្លា*

ហ្វ្រង់ស្វ័រ រូហ្ស គឺជាមេធាវីការពារក្តីអន្តរជាតិរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ លោក គឺជាមេធាវីជនជាតិបារាំង ដែលបានប្រតិបត្តិលើវិស័យច្បាប់អស់រយៈពេលជាង៣៥ឆ្នាំមកហើយ ។ លោកបានចំណាយពេលជាច្រើនឆ្នាំនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសរ៉្វាន់ដា ដែលនៅទីនោះលោកបានការពារជនត្រូវចោទចំនួន៤រូប និងទទួលនូវសាលក្រមវិនិច្ឆ័យថា គ្មានទោសចំនួនមួយរូប ។ លោកក៏ជាមេធាវីការពារក្តីឲ្យ ហ្សាខារាស មូសូអ៊ី ដែលមានជាប់ពាក់ព័ន្ធនឹងការវាយប្រហារនៅថ្ងៃទី១១ ខែកញ្ញា នៅទីក្រុងញូវយ៉ក ។ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ហ្វ្រង់ស្វ័រ រូហ្ស បានអត្ថាធិប្បាយពិភាក្សាពីតួនាទី និងសារសំខាន់នៃការជំនុំជម្រះក្តីរបស់ ឌុច ជាមួយក្រុមឃ្លាំមើលសាលាក្តីខ្មែរក្រហម ។

**ស៊ី.ធី.អឹម** : នៅអំឡុងពេលសវនការ ឌុច បានទទួលស្គាល់ពីទោសកំហុសរបស់ខ្លួនជាច្រើនចំណុចជាច្រើន ។ នៅក្រោមច្បាប់ ខមិនឡ ជនត្រូវចោទដែលទទួលស្គាល់ទោសរបស់ខ្លួនមិនត្រូវទទួលការជំនុំជម្រះលើបទល្មើសរបស់ខ្លួនពេញលេញទេ ។ តើលោកគិតថាវាមានសារសំខាន់ដែរឬទេដែលត្រូវឆ្លងកាត់ដំណើរការនេះ? ឬតើវាល្អដែរឬទេប្រសិនបើ ឌុច ឈានទៅដល់ដំណាក់កាលផ្តន្ទាទោសតែម្តង?

**រូហ្ស** : ដោយនេះ គឺជាការជំនុំជម្រះលើកដំបូងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូច្នេះការដែលមានអ្នកជំនាញ និងសាក្សីមកផ្តល់សក្ខីកម្មដើម្បីបង្កើតជាកំណត់ត្រាប្រវត្តិសាស្ត្រដែលបានកើតឡើងនៅគុកទួលស្លែង(ស-២១) គឺមានសារសំខាន់ ។ ប្រសិនបើ ឌុច ឈានទៅដល់ការផ្តន្ទាទោសតែម្តង នោះវានឹងធ្វើឲ្យប្រជាជនកម្ពុជាមិនសប្បាយចិត្ត ។ ខ្ញុំជឿថា យើងអាចសម្រេចបាននូវលទ្ធផលនេះនៅក្នុងបរិបថដែលសាលក្រមវិនិច្ឆ័យថាមានទោស ហើយដែលនៅក្នុងនោះមេធាវីការពារក្តី និងព្រះរាជអាជ្ញាសុទ្ធតែយល់ស្របនឹងឲ្យមានអ្នកជំនាញនិងសាក្សីមកផ្តល់សក្ខីកម្មនៅតុលាការជាសាធារណៈ ។ ប៉ុន្តែព្រះរាជអាជ្ញាមិនចង់ដើរតាមទម្រង់ការផ្សារនេះទេ ។ វាគឺជារឿងមិនទំនងមួយ ពីព្រោះវាមិនសាក

សមនឹងឲ្យ ឌុច សារភាពទោសនៅពេលជាមួយគ្នាដែលមានសាក្សីរៀបរាប់ពីរឿងរបស់ខ្លួននៅក្នុងតុលាការដើម្បីបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រ ។ វាគួរតែជាដំណើរការដ៏រលូនមួយ ប៉ុន្តែយើងត្រូវទាញទៅដល់ស្ថានភាពដ៏ចម្លែកមួយដែលមានព្រះរាជអាជ្ញាព្យាយាមអះអាងពីពិរុទ្ធភាពរបស់ ឌុច ដែលគាត់បានយល់ស្របនិងទទួលស្គាល់រួចទៅហើយ ។

**ស៊ី.ធី.អឹម** : លោកបានលើកឡើងប៉ុន្មានដងថា ដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែមានការភ័ន្តច្រឡំរវាងតួនាទីរបស់ខ្លួនដោយប្រតិបត្តិដូចជាព្រះរាជអាជ្ញា ។ តើលោកយល់យ៉ាងថា អ្វីគួរតែជាតួនាទីសមស្របរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងករណីបន្តបន្ទាប់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬនៅក្នុងតុលាការអចិន្ត្រៃដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិ?

**រូហ្វ** : តាមគោលការណ៍ ខ្ញុំពេញចិត្តនឹងការចូលរួមរបស់ជនរងគ្រោះនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ប៉ុន្តែនៅក្នុងចំណុចនេះ យើងមិនទាន់បានបង្កើតជាគំរូដ៏ល្អមួយសម្រាប់ការចូលរួមបែបនេះនៅឡើយទេ ។ យើងបានគិតថា យើងអាចប្រើប្រាស់ច្បាប់ស៊ីវិលសម្រាប់ជំនុំជម្រះបទឧក្រិដ្ឋ ប៉ុន្តែ ឥឡូវយើងឃើញច្បាស់ហើយថា យើងមិនអាចប្រើប្រាស់ច្បាប់នេះដោយមិនមានការកែប្រែអ្វីទេ ។ វាមិនបានន័យថា យើងគួរតែបោះបង់ការចូលរួមរបស់ជនរងគ្រោះឡើយ ។ ប៉ុន្តែ ក្នុងនាមជាមេធាវីយើងចាំបាច់ត្រូវតែបេះច្នៃប្រឌិត និងកែប្រែគំរូ ដើម្បីឲ្យស្របទៅតាមតម្រូវការពិសេសរបស់តុលាការ ។ ការជំនុំជម្រះក្តី ឌុច បានបង្ហាញពីឧបសគ្គមួយចំនួនទាក់ទងនឹងគំរូបច្ចុប្បន្ន ។ កិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានរកឃើញការផ្លាស់ប្តូរជាវិជ្ជមានគំរូមួយ សម្រាប់ការកាត់សេចក្តីនៅពេលអនាគត ដូចជាការអនុញ្ញាតិឲ្យការតំណាងជនរងគ្រោះជារួម ។ យើងត្រូវតែធានាថា វត្តមានដ៏ច្រើនរបស់ជនរងគ្រោះមិនប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទ ។ យើងគួរតែស្វែងរកវិធានមួយសម្រាប់ការចូលរួមរបស់ជនរងគ្រោះនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ យើងគួរតែចាប់ផ្តើមដោយប្រព័ន្ធច្បាប់ស៊ីវិល ហើយកែប្រែវា ដើម្បីដោះស្រាយនឹងឧសគ្គនៃការការជំនុំជម្រះក្តីនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

**ស៊ី.ធី.អឹម** : លោកបានលើកឡើងប៉ុន្មានដងថា ឌុច គឺជាមនុស្សដំបូង និងជាមេដឹកនាំខ្មែរក្រហមតែម្នាក់ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់គាត់ ។ ជាមួយនឹងការទទួលស្គាល់បទឧក្រិដ្ឋ និងស្ថានសម្រាលទោស តើអ្វីគឺជាផ្តន្ទាទោសដ៏ត្រឹមត្រូវ? ហើយតើលោកឆ្លើយតបនឹង

អ្នកដែលនិយាយថា នឹងមិនមានការបន្ថយទោសចំពោះសកម្មភាពរបស់ដែលបានសម្លាប់មនុស្សរាប់ពាន់នាក់ទេដោយរបៀបណា?

**រូហ្ស** ៖ យុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ បានបញ្ជាក់ពីស្ថានសម្រាលទោសជាក់លាក់មួយចំនួនដែលគួរតែយកមកពិចារណានៅពេលសម្រេចការផ្តន្ទាទោស ។ ជាឧទាហរណ៍ ការដែលធ្វើតាមបញ្ជាថ្នាក់លើមិនអាចធ្វើឲ្យជនត្រូវចោទរួចខ្លួនចេញពីបទល្មើសអន្តរជាតិទេ វាគ្រាន់តែអាចសម្រាលការផ្តន្ទាទោសប៉ុណ្ណោះ ។ នៅក្នុងករណីរបស់ ឌុច គាត់មិនត្រឹមតែធ្វើតាមបញ្ជាថ្នាក់លើទេ តែថែមទាំងអនុវត្តដោយផ្តាច់ការទៀតផង ។ នៅក្នុងករណីនោះ សូម្បីតែការចេញមតិឬផ្តល់យោបល់ ក៏អាចបណ្តាលឲ្យមានការស្លាប់ដែរ ។

វាហាក់ដូចជាលឿនពេកក្នុងការឆ្លើយតបនឹងរយៈពេលនៃការផ្តន្ទាទោស ។ ប៉ុន្តែសេចក្តីសម្រេចមួយចំនួនរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតបង្ហាញថា ការផ្តន្ទាទោសធ្ងន់បំផុតដោយឲ្យជាប់ពន្ធនាគារមួយជីវិតគឺមិនសាកសមទេ ទោះបីជានៅក្នុងករណីព្រហ្មទណ្ឌដែលមានស្ថានសម្រាលទោសជាក់លាក់ក៏ដោយ ។ ដូច្នេះ វាគឺជាតួនាទីរបស់អង្គជំនុំជម្រះសម្រាប់សម្រេចការផ្តន្ទាទោសដ៏សមរម្យមួយ ។

**ស៊ី.ធី.អ៊ឹម** ៖ រដ្ឋាភិបាលកម្ពុជា និងបុគ្គលិកជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រឆាំងមិនឲ្យមានការស៊ើបអង្កេតលើបទល្មើសបន្ថែម ។ ដោយយោងទៅតាមអង្គហេតុដែលថាមានមនុស្សជាច្រើនជាប់ពាក់ព័ន្ធនឹងខ្មែរក្រហម ហើយមានមេដឹកនាំជាច្រើនទៀតដែលត្រូវបានចាត់ទុកថា មានឋានៈខ្ពស់ជាង ឌុច តើលោកយល់ថាអ្នកផ្សេងទៀតគួរតែត្រូវបានកាត់ទោសដូច ឌុច ដែរឬទេ?

**រូហ្ស** ៖ តុលាការមិនគួរសម្រេចថាត្រូវចោទប្រកាន់អ្នកណាទេ ពីព្រោះវាយោងទៅតាមគោលការណ៍នៃសញ្ញាណយុត្តិធម៌ ។ ប៉ុន្តែ តុលាការគួរតែកាត់ទោសអ្នកដែលបានប្រព្រឹត្ត គឺមិនមែនកាត់ទោសអ្នកដែលបានតំណាងទេ ។ ម្យ៉ាងវិញទៀត ខ្ញុំយល់ពីតួនាទីរបស់រដ្ឋាភិបាលដែលបានបង្កើតសន្តិភាពជាមួយសត្រូវរបស់ខ្លួន ហើយចង់ការពារសន្តិភាពដែលងាយនឹងបាក់បែក ។ ប៉ុន្តែវាក៏មានសារសំខាន់ក្នុងការដោះស្រាយនូវបញ្ហានៃការផ្សះផ្សាជាតិចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅអតីតកាល ។ អំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺកាត់ទោសមេដឹកនាំជាន់ខ្ពស់ ខ្មែរក្រហម ហើយវាក៏មានមេដឹកនាំជាច្រើនផ្សេងទៀតដែលមានតួនាទីខ្ពស់ជាង ឌុច ដែរ ។ អ្វីដែលសំខាន់គឺ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែសម្រេចឲ្យបាននូវតុល្យភាព ប៉ុន្តែខ្ញុំយល់ថា ការកាត់ទោសជន

ត្រូវចោទត្រឹមតែ៥នាក់មិនមានតុល្យភាពទេ ហើយក៏ហាក់ដូចជាមិនមានប្រសិទ្ធភាពនៅក្នុងភ្នែករបស់សាធារណជនកម្ពុជាដែរ ។

**ស៊ី.ធី.អឹម** : ប្រជាជនជាច្រើនមានទស្សនៈខុសៗគ្នា ទៅលើតួនាទីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អ្នកខ្លះយល់ថាគោលបំណងចម្បងគឺត្រូវសម្រេចឲ្យបាននូវការផ្សះផ្សាជាតិ ប៉ុន្តែអ្នកខ្លះយល់ថាគឺគោលបំណងចម្បងគឺដើម្បីបញ្ឈប់វប្បធម៌នៃនិទណ្ឌភាព ឬដើម្បីផ្ដន្ទាទោសអ្នកដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ។ ដោយចំណុចទាំងនេះហាក់ដូចជាមិនដូចគ្នា ដូច្នេះតើអ្វីជាតួនាទីត្រឹមត្រូវនឹងគោលបំណងចម្បងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា?

**រូហ្វ** : ព្រះរាជអាជ្ញា ចៅក្រម និងរដ្ឋាភិបាលកម្ពុជាសុទ្ធតែមានតួនាទីផ្សេងគ្នា ។ ខណៈពេលដែលតួនាទីរបស់ចៅក្រមគឺត្រូវរួមចំណែកក្នុងដំណើរការផ្សះផ្សាជាតិ និងបញ្ឈប់វប្បធម៌និទណ្ឌភាព វាមិនមែនជាគោលដៅចម្បងរបស់អ្នកទាំងនោះទេ ។ នៅពេលដែលចៅក្រមធ្វើសច្ចាប្រណិធាន អ្នកទាំងនោះត្រូវតែបូជាដើម្បីសម្រេចឲ្យបាននូវគោលបំណងតែមួយដើម្បីសម្រេចបាននូវយុត្តិធម៌ ដោយធ្វើការចេញសេចក្ដីសម្រេចយោងទៅតាមវិធានច្បាប់ ។ ដូចគ្នាដែរ ព្រះរាជអាជ្ញាក៏មានតួនាទីប្រឆាំងនឹងវប្បធម៌នៃនិទណ្ឌភាព រីឯរដ្ឋាភិបាលមានតួនាទីស្វែងរក និងសម្រេចនូវការផ្សះផ្សាជាតិ ។ ជាឧទាហរណ៍ ការងារទាំងនេះអាចសម្រេចទៅបានតាមរយៈ គណៈកម្មាការផ្សះផ្សានិងស្វែងរកការពិត ។